អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
-----------

# សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង
# អំពីការតែងតាំងជាប្រធានសាលាឧទ្ធរណ៍

ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលនាពេលថ្មីៗនេះ ខ្ញុំត្រូវបានតម្លើងតំណែងជាប្រធានសាលាឧទ្ធរណ៍ នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

មុខតំណែងថ្មីនេះនឹងអនុញ្ញាតអោយខ្ញុំមានតួនាទីសំខាន់មួយនៅក្នុងដំណើរការនៃកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និង ច្បាប់ ជាពិសេសក្នុងភារកិច្ចអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមនីតិវិធីព្រហ្មទណ្ឌដែលទើបត្រូវបានប្រកាសអោយប្រើនាពេលថ្មីៗនេះ។ សាលាឧទ្ធរណ៍ដែលជាសាលាជម្រះក្តីជាន់ខ្ពស់មួយនៃព្រះរាជាណាចក្រកម្ពុជាមានតួនាទីដ៏សំខាន់ក្នុងការធានាការបកស្រាយច្បាប់ និង ការអនុវត្តច្បាប់អោយមានលក្ខណៈឯកភាពនៅក្នុងប្រទេស។ ដោយផ្អែកលើបទពិសោធន៏ដែលខ្ញុំមាន ជាពិសេសបទពិសោធន៏ដែលទទួលបានក្នុងអំឡុងពេលបំពេញភារកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញ ខ្ញុំអាចមានលទ្ធភាពច្រើនថែមទៀតក្នុងការរួមចំណែកក្នុង ការកែទម្រង់ និងពង្រឹងប្រព័ន្ធយុត្តិធម៌ និងការអនុវត្តច្បាប់នៅកម្ពុជាដែលជាអាទិភាពយូរអង្វែងរបស់ជាតិ។

ស្របពេលជាមួយគ្នានេះដែរ ភារកិច្ចរបស់ខ្ញុំជាសហចៅក្រមស៊ើបអង្កេតជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ ក៏មានសារៈសំខាន់សម្រាប់ប្រទេសខ្ញុំ និងមនុស្សជាតិទាំងមូល ។ ដ៏រាបណាអង្គជំនុំជម្រះវិសាមញ្ញចាត់ទុកវត្តមានរបស់ខ្ញុំមានភាពចាំបាច់ ដ៏រាបនោះខ្ញុំមានករណីយកិច្ចបន្តការងារដើម្បីធានាថាមិនមានភាពរអាក់រអួល ឬការពន្យារពេលនៃដំណើរការក្តីនេះ។ ខ្ញុំនឹងបន្តភារកិច្ចរបស់ខ្ញុំនៅអង្គជំនុំជម្រះវិសាមញ្ញរហូតដល់ពេលវេលាមួយដែលមានការផ្ទេរការងារប្រព្រឹត្តទៅដោយភាពរលូន និងសមស្រប។ ខ្ញុំបានចាប់ផ្តើមពិគ្រោះយោបល់ជាមួយបុគ្គលិក និងសមភាគីអន្តរជាតិរបស់ខ្ញុំ ដើម្បីស្វែងរកនូវដំណោះស្រាយមួយប្រកបដោយន័យស្ថាបនា និងភាគីទាំងពីរអាចទទួលយកបានដែលនឹងមិនធ្វើអោយប៉ះពាល់ដល់ដំណើរការនៃការងាររបស់យើងឡើយ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
-----------

យើងទទួលស្គាល់ថា អនុលោមតាមច្បាប់ស្តីពីការបង្កើត**អង្គជំនុំជម្រះវិសាមញ្ញ** និង កិច្ចព្រមព្រៀងឆ្នាំ២០០៣ សហចៅក្រមស៊ើបអង្កេតត្រូវបានតែងតាំងសំរាប់រយៈពេលនៃការស៊ើបអង្កេត ។ ទោះជាយ៉ាងនេះក្តី ក៏លិខិតុបករណ៍ទាំងពីរបានចែងអំពីការតែងតាំងសហចៅក្រមស៊ើបអង្កេតបម្រុងផងដែរ ជាការបញ្ជាក់ថាយើងបានព្រាងគិតទុកជាមុនចំពោះលទ្ធភាពនៃការផ្លាស់ប្តូរនេះ ។ អង្គជំនុំជម្រះវិសាមញ្ញក៏ដូចជាតុលាការផ្សេងទៀតដែរ ត្រូវតែចែងអំពីយថាភាពដែលចៅក្រមជាតិ ឬ អន្តរជាតិណាម្នាក់មិនមានលទ្ធភាពក្នុងការបំពេញមុខងាររបស់ខ្លួនក្នុងកាលៈទេសៈពិសេស។

ខ្ញុំជឿជាក់ថា ការរៀបចំដែលយើងកំពុងអនុវត្តចំពោះស្ថានភាពថ្មីនេះស្របទាំងស្រុងជាមួយនឹងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

ភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០០៧